Priez depuis le Ciel pour l'Eglise du Cambodge afin que nous soyons dignes de la servir et de chercher le Royaume de Dieu sur cette terre des dieux.

Joie, Charité, Compassion, Souffrance étaient mêlées à votre sourire.

Souriez, riez encore et encore en nous regardant depuis le Ciel, afin que nous aussi, nous laissions façonner notre visage et notre cœur à l'image de Dieu.

Monseigneur Yves, soyez en Paix pour l'éternité et saluez nos frères et sœurs dans la foi, Mgr Chmar Salas, ses compagnons et tous les autres.

*« Bon ... »* c'était votre petit mot quand les déjeuners s'éternisaient à l'évêché pour que nous nous levions de table.

Dans le silence de ce 25 février, certainement que Dieu vous a susurré : *« Bon »*. A l'image de votre vie, vous avez alors répondu dans un dernier souffle : ***« ME VOICI SEIGNEUR ! ».***

À DIEU.

+ OLIVIER SCHMITTHAEUSLER
Vicaire Apostolique de Phnom Penh
CAMBODGE

# បុត្រមនុស្សមកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោកទេ គឺលោកមកបម្រើគេវិញ

ចម្លងទេសនាលោកអភិបាល អូលីវីយេ ក្នុងអភិបូជាបុណ្យសព និងបញ្ចុះសពរបស់លោកអភិបាល អ៊ីវ រ៉ាមូស
នៅប្រទេសបារាំង ម៉ោង ០៣:០០ រសៀល ត្រូវនឹងម៉ោង ០៩:០០ យប់ នៅប្រទេសកម្ពុជា
ចំការទ្បេង ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

**អត្ថបទទី១៖ យេរេមី ១៨,១៨-២០**

**ពុំដែលមាននរណាប្រព្រឹត្តអំពើអាក្រក់ តបនឹងអំពើល្អទេ។** *យរ ១៨,២០*

**ដំណឹងល្អ៖ ម៉ាថាយ ២០,១៧-២៨**

**អ្នកចង់បានអ្វី?** *មថ ២០,២១*



បងប្អូនជាទីគោរពស្រឡាញ់!

ពេលនេះ ដែលយើងកំពុងចូលរួមពីចម្ងាយតាមរូបកាយ ប៉ុន្តែពីជិតតាមផ្លូវវិញ្ញាណនិងផ្លូវចិត្តជាមួយលោកអភិបាល អ៊ីវ ដែលកំពុងចូលនៅក្នុងពិធីបុណ្យសពផ្ទាល់ខ្លួន ។ យើងនឹករលឹកដល់ជីវិតរបស់គាត់ម្តងទៀត តាមពិតនៅពេលយើងបានស្តាប់ប្រវត្តិសាស្ត្រសង្ខេបរបស់លោក ខ្ញុំបានជ្រើសរើសបន្ទរមួយដែលថា **"ចូរមានចិត្តមេត្តាដូចព្រះបិតា"** ខ្ញុំគិតថានេះជារបៀបដែលលោក អ៊ីវ បានអនុវត្តព្រះបន្ទូលរបស់ព្រះជាម្ចាស់អស់មួយជីវិតរបស់លោក ។ ដោយទុកនៅក្នុងដួងចិត្តថា **"ខ្ញុំជាអ្នកបម្រើដែលព្រះជាម្ចាស់បានជ្រើសរើស ជីវិតរបស់ខ្ញុំធ្វើដូចម្តេច ដើម្បីឱ្យខ្ញុំបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ នៅក្នុងគ្រប់សកម្មភាពនៃជីវិតរបស់ខ្ញុំ"** ។ តាមពិតជីវិតរបស់លោក អ៊ីវ ប្លែកប្រៀបបីដូចមានជីវិតពីរ ជីវិតមុនសម័យប៉ុលពត ដែលជាប់នឹងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៥៧ រហូតដល់ឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមបណ្តេញគាត់ពីស្ថានទូតបារាំង ជាមួយជនជាតិបរទេសប៉ុន្មាននាក់ ។ គេបានធ្វើដំណើរ ពីទីក្រុងភ្នំពេញរហូតដល់ព្រំដែននៃប្រទេសថៃ កាត់ប៉ោយប៉ែត គាត់ត្រឡប់មកវិញ (លោក អ៊ីវ) នៅឆ្នាំ១៩៨៩ តែងតាំងជាអភិបាលសារជាថ្មី ។ តាមពិតនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក មានតែលោកមួយដែលធ្វើជាអភិបាលពីរដងនៅភូមិភាគតែមួយ នៅឆ្នាំ១៩៩២ បន្តតួនាទីដែលគាត់ទទួលពីសម្តេចប៉ាប ។

នៅក្នុងជីវិតទាំងពីររបស់លោក តាមពិតជាជីវិតតែមួយ យើងមានសញ្ញាមួយដែលណែនាំឱ្យយើងត្រូវការនឹករលឹកជីវិតរបស់គាត់ ដូចជាគាត់ឆ្លងពីសម័យប៉ុលពតចូលនៅក្នុងសម័យថ្មីនេះ ។ យើងធ្លាប់ស្គាល់ឈើឆ្កាងនេះ (ឈើឆ្កាងរបស់លោកអភិបាល) ឈើឆ្កាងនេះជាសញ្ញាដ៏ពិសេស ជាឈើឆ្កាងដែលគាត់ប្រគល់ដល់លោក ឆ្មារ សាឡាស់ នៅពេលគាត់តែងតាំងលោក ឆ្មារ សាឡាស់ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥ ។ នៅពេលនោះទីក្រុងភ្នំពេញវេទនាណាស់ គឺជិតដល់ពេលវេលាដែលខ្មែរក្រហមចូល ។ គាត់ថ្វាយអភិបូជានៅវិសាលវិហារមិនបាន គាត់ក៏ថ្វាយអភិបូជានៅក្នុងព្រះវិហារដ៏តូចមួយ ដែលយើងមាននៅជាប់នៅផ្សារតូច ជាប់នឹងស្ថានជ្រោយចង្វារឈ្មោះព្រះវិហារព្រះមាតា ។ នៅពេលនោះ មានគ្នាតិចណាស់មានគ្រីស្តបរិស័ទតែប៉ុន្មាននាក់ដើម្បីតែងតាំងលោកអភិបាលមួយអង្គ ត្រូវមានលោកអភិបាលបីអង្គយ៉ាងតិច ។ នៅពេលនោះ មានតែលោក អ៊ីវ និងលោកអភិបាល ឡេស្វេស ដែលទទួលខុសត្រូវនៅកំពង់ចាម លោក អ៊ីវ បានប្រគល់ឈើឆ្កាងនេះទៅឲ្យ ឆ្មារ សាឡាស់ ។ ឈើឆ្កាងនេះជាអនុស្សាវរីយ៍តែមួយគត់ ដែលនៅសល់របស់ព្រះសហគមន៍កាតូលិកនៅកម្ពុជាមុនឆ្នាំ១៩៧៥ ។ ប៉ុលពត និងខ្មែរក្រហមបានវាយបោលព្រះវិហារទាំងអស់ដែលយើងមាន បានដុតគ្រប់ឯកសារដែលយើងមានពីដើម បានយកទ្រព្យសម្បត្តិទាំងអស់នៅក្នុងព្រះសហគមន៍ ទាំងដី ទាំងមនុស្ស ។ នៅពេលនោះគ្រីស្តបរិស័ទបានស្លាប់ច្រើនណាស់ ហើយឈើឆ្កាងនេះអត់បានបាត់ ជាសញ្ញាតែមួយគត់ដែលណែនាំឱ្យយើងឆ្លងជំនឿនៃជីវិតរបស់គ្រីស្តបរិស័ទនៅឆ្នាំ១៩៧៥ ដើម្បីចូលនៅក្នុងឆ្នាំ១៩៩០ ។ លោក ឆ្មារ សាឡាស់ ដែលបានទទួលប្រគល់ឱ្យម្តាយរបស់គាត់ ហើយម្តាយគាត់បានទុករហូតផុតសម័យខ្មែរក្រហមនៅក្រោមសម្បុកមាន់ ។

ដូច្នេះ ឈើឆ្កាងនេះពោរពេញដោយអត្ថន័យ ក្រោយមកលោក អេមីល ដែលបានទទួល ក្រោយមកទៀតខ្ញុំ តាមពិតលោកអភិបាល អ៊ីវ ជាអភិបាលទី២៣ ដែលទទួលខុសត្រូវភូមិភាគភ្នំពេញ និងលោក អេមីល ជាអភិបាលទី២៤ និងខ្ញុំជាអភិបាលទី២៥ ។ បងប្អូនដែលជាគ្រីស្តបរិស័ទជាពិសេសនៅចំការទៀងយើង ដែលជាគ្រីស្តបរិស័ទខ្មែរសុទ្ធបានទទួលអគ្គសញ្ញាជ្រមុជទឹកចំនួន៣៣៦នាក់ គូស្រករដែលបានទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ចំនួន៥៣គូ ហើយបានបង្កើតកូនចៅនៅក្នុងខេត្តតាកែវ៧ព្រះសហគមន៍ទៀត ។ តាមពិត នេះជាផ្លែរបស់លោកអភិបាល អ៊ីវ រ៉ាមូស បងប្អូនប្រហែលមិនស្គាល់លោកអភិបាល អ៊ីវ មានតែអ្នកចាស់ៗទើបស្គាល់លោក យើងជាព្រះសហគមន៍កាតូលិកកម្ពុជា យើងជាផ្លែរបស់គាត់ ។ ដោយសារគាត់ ព្រះសហគមន៍របស់យើងនៅឆ្នាំ១៩៦៥ បានសម្រេចចិត្តប្រើភាសាខ្មែរជាភាសាផ្លូវការសម្រាប់ថ្វាយអភិបូជា សម្រាប់អប់រំជំនឿ សម្រាប់អានគម្ពីរដំណឹងល្អ ។ ជាលោកដែលបានសម្រេចចិត្តស្នើសុំសន្តអាសនៈ បែងចែកព្រះសហគមន៍កាតូលិកនៅកម្ពុជាជាបីភូមិភាគ ។ ពេលគាត់ទទួលអគ្គសញ្ញាតែងតាំងជាអភិបាលមានអាយុតែ៣៥ឆ្នាំ គាត់បានទទួលព្រះសហគមន៍ក្នុងប្រទេសកម្ពុជាទាំងមូល ។ នៅឆ្នាំ១៩៦៨ បានចែកឱ្យមានបាត់ដំបងជាមួយលោកអភិបាល ទេព អ៊ីម (បូជាចារ្យខ្មែរ) និងកំពង់ចាមជាមួយលោកអភិបាល ឡេស្វេស (ក្រុមMEP) ។ ការបែងចែកព្រះសហគមន៍ជាបីភូមិភាគ បានណែនាំឱ្យគ្រីស្តបរិស័ទក៏ដូចជាព្រះសហគមន៍ មានភាពជិតស្និទ្ធជាមួយគ្រូគង្វាលផ្ទាល់ខ្លួន និងណែនាំឱ្យព្រះសហគមន៍អាចធ្វើដំណើរបន្តិចម្តងៗ ដើម្បីចាក់គ្រឹះនៅប្រទេសកម្ពុជា ។ នៅពេលគាត់ ត្រលប់មកពីចូលរួមមហាសន្និបាតវ៉ាទីកង់ទី២នៅទីក្រុងរ៉ូម ដែលចង់ឱ្យព្រះសហគមន៍ទទួលដង្ហើមថ្មី ដើម្បីកសាងព្រះសហគមន៍របៀបថ្មី ។ គាត់បានណែនាំឱ្យបន្តិចម្តងៗ ជាពិសេសតាមរយៈពិធីបុណ្យ តាមរយៈឥរិយាបថ តាមរយៈកាយវិការ តាមរយៈអគ្គសញ្ញាអាពាហ៍ពិពាហ៍ជាដើម បានណែនាំឱ្យវប្បធម៌នៃប្រទេសកម្ពុជាចូលយ៉ាងជ្រៅ នៅក្នុងជីវិតនៃព្រះសហគមន៍ ។ ណែនាំឱ្យយើងយល់ថា ព្រះសហគមន៍មិនមែនជាព្រះសហគមន៍ដែលមកពីបរទេស តែជាព្រះសហគមន៍កាតូលិក

ដែលបានចាក់គ្រឹះលើទឹកដីប្រទេសកម្ពុជា ។ នៅសម័យនោះ គាត់ជាអភិបាលម្នាក់ឯងក្នុងប្រទេសកម្ពុជា នៅទីក្រុងរ៉ូមសុំឱ្យបង្កើតក្រុមលោកអភិបាលតាមប្រទេសនីមួយៗ គាត់បានជ្រើសរើសប្រទេសឡាវធ្វើជាក្រុមលោកអភិបាលតែមួយជាមួយខ្មែរយើង ។ យើងប្រជុំម្តងនៅប្រទេសឡាវម្តងនៅប្រទេសកម្ពុជា ក្រុមលោកអភិបាលនេះបានធ្វើដំណើរជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ ប្រវត្តិសាស្ត្រ បរិយាកាសនៃជីវិត របៀបរស់នៅ របៀបបង្កើតទំនាក់ទំនងឡាវនិងកម្ពុជាស្រដៀងគ្នាណាស់ លោកអភិបាល អ៊ីវ មានទស្សនៈវែងឆ្ងាយដើម្បីរៀបចំទាំងអស់ ។

ប្រហែលគាត់ឥតមានម្តាយ ដែលសុំព្រះជាម្ចាស់ឱ្យកូននៅកន្លែងនេះកន្លែងនោះ ដូចអត្ថបទដែលយើងបានស្តាប់ថ្ងៃនេះ ។ ប៉ុន្តែ គាត់បានទទួលពែងនៃទុក្ខលំបាកដ៏ពេញលក្ខណៈ ជាពិសេសនៅឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ នៅឆ្នាំ១៩៧០ ព្រះសហគមន៍របស់យើងដែលមានជនជាតិវៀតណាមច្រើន ទៅជាព្រះសហគមន៍មួយដ៏តូចវិញ ដោយសារពេលនោះ ជនជាតិវៀតណាមបានទៅប្រទេសវៀតណាមវិញទាំងអស់ ។ លោកអភិបាល អ៊ីវ បានឃើញឈាមនៃគ្រីស្តបរិស័ទ ដោយសារគេកាត់ករជនជាតិវៀតណាម៦៧៥នាក់ ដែលជាគ្រីស្តបរិស័ទ នៅពេលនោះទឹកទន្លេមេគង្គឡើងពណ៌ក្រហម ដោយសារឈាមរបស់គ្រីស្តបរិស័ទ ។ លោកអភិបាល អ៊ីវ បានឃើញផ្ទាល់ភ្នែកណែនាំឱ្យលោកឈឺចាប់ណាស់ នៅក្នុងឆ្នាំនោះគ្រីស្តបរិស័ទវៀតណាម សាសនទូត បងស្រីបានចេញទៅអស់ហើយ នៅសល់តែគ្រីស្តបរិស័ទខ្មែរប៉ុន្មាននាក់ ។ គាត់បានបង្កើតក្រុមបូជាចារ្យខ្មែរ ដែលមានលោក ឆ្មារ សាឡាស់ លោក ឆ្មារ សាឡឹម លោក សំរើន ដែលគាត់បានតែងតាំងនៅប្រទេសកម្ពុជា ។ គាត់បានឃើញសង្គ្រាមស៊ីវិលមានលក្ខណៈពិបាកទៅៗ គាត់បានបង្កើតក្រុមសង្គហៈ(ការីតាស) ដើម្បីជួយបងប្អូនដែលកំពុងរងទុក្ខលំបាក ។ នៅឆ្នាំ១៩៧៥ ពេលគេវាយស្ពានជ្រោយចង្វារបោល នៅពេលនោះលោកអភិបាល អ៊ីវ យល់ថាដល់ពេលវេលាគិតអំពីអនាគតគាត់មិនអាចនៅប្រទេសកម្ពុជាបានយូរទេ ។ តែនៅពេលមានយន្តហោះចុងក្រោយដែលចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងគាត់មិនបានទៅទេ (មានលោកតា ប៉ុងស្វូ លោក អេមីល លោកតា វើណេ និងលោក អ៊ីវ)។ យើងមានលោកបួនអង្គ ដែលបានសម្រេចចិត្តទោះមានអ្វីកើតឡើង យើងនៅជាមួយប្រជារាស្ត្ររបស់យើង ។ នៅពេលនោះ គាត់បានហៅលោក ឆ្មារ សាឡាស់ ដែលកំពុងរៀននៅប្រទេសបារាំងឱ្យត្រឡប់មកកម្ពុជាវិញ ។ ខ្ញុំមានសំបុត្ររបស់លោក ឆ្មារ សាឡាស់ ដែលបានសរសេរនៅខែមករា ឆ្នាំ១៩៧៥ថា **“ដល់ពេលវេលាដែលខ្ញុំត្រលប់ទៅប្រទេសកម្ពុជាវិញ ខ្ញុំមិនដឹងមានអ្វីដែលកើតឡើង ប៉ុន្តែខ្ញុំទៅដើម្បីជាប់ជាមួយបងប្អូនខ្ញុំ”** ។ នៅពេលគាត់មកដល់កម្ពុជាវិញ លោកអភិបាល អ៊ីវ បានតែងតាំងលោក ឆ្មារ សាឡាស់ ជាអភិបាលភ្លាម ។ ពីរថ្ងៃក្រោយមក លោក សាឡឹម លោក សំរើន លោក សាឡាស់ លោក វ៉ាមូស លោក អេមីល លោកតា ប៉ុងស្វូ និងលោកតា វើណេ បានជួបជុំគ្នានៅផ្ទះលោកអភិបាលផ្លូវមុនីវង្ស (សាលារាជធានីភ្នំពេញសព្វថ្ងៃ) ថាដល់ពេលវេលាយើងបែកគ្នា ។ លោកអភិបាល ឆ្មារ សាឡាស់ បានប្រាប់ទៅសាសនទូតទាំងបួនថា **“សូមប្រាប់ពិភពលោកអំពីជីវិតយើងនៅកម្ពុជា”** ។

លោកអភិបាល អ៊ីវ គាត់ឈឺចាប់ណាស់ដោយព្រះសហគមន៍ដែលគាត់ស្រឡាញ់បាត់ទាំងអស់ បាត់បង់បងប្អូន បាត់ក្រុមមេត្តាករុណា បាត់សកម្មភាពទាំងអស់ ។ ពីមុននៅតាមទីរួមខេត្តនីមួយៗ មានព្រះវិហារកាតូលិកទាំងអស់ តែត្រូវគេវាយកំទិចចោលអស់ នៅសល់តែកំពង់សោម បូកគោ នឹងផ្សារតូច ។ នៅឆ្នាំ១៩៨៩ គាត់ត្រលប់មកកម្ពុជាវិញ គាត់ចូលនៅក្នុងគម្ពីរដែលយើងបានស្តាប់ថ្ងៃនេះទៀត **“ពែងនៃទុក្ខលំបាកមិនទាន់ពេញទេ”** គាត់ឈឺចិត្តថែមទៀត ។ ពេលនោះ ជនជាតិខ្មែរគ្មានសិទ្ធិមានទំនាក់ទំនងជាមួយជនជាតិបរទេសទេ គាត់បានដើរតាមផ្លូវមុនីវង្សដោយសង្ឃឹមថាមានគ្រីស្តបរិស័ទណាម្នាក់ឃើញគាត់ ។ ពិតមែនពេលនោះ មានគ្រីស្តបរិស័ទម្នាក់បានឃើញ

គាត់ ហើយគេបានធ្វើសញ្ញាមួយប្រាប់លោក អ៊ីវ ថាទៅជួបជុំគ្នានៅភោជនីយដ្ឋានមួយស្ងាត់ៗ ។ ពេលនោះ លោក អ៊ីវ មួកលោកអភិបាលក៏គ្មាន ដំបងលោកអភិបាលក៏គ្មាន គាត់នៅសល់តែចិញ្ចៀនដែលជាសញ្ញាសម្គាល់នៃភក្ដីភាពរបស់គាត់ ជាមួយព្រះជាម្ចាស់ ជាមួយព្រះសហគមន៍កម្ពុជា ជាពិសេសភក្ដីភាពរបស់ព្រះជាម្ចាស់ចំពោះគាត់ និងភក្ដីភាពរបស់គ្រីស្ដបរិស័ទ ។ ព្រះសហគមន៍ពេលនោះចាប់ផ្ដើមរស់ឡើងវិញបន្តិចម្ដងៗ នៅឆ្នាំ១៩៩២គាត់ត្រូវបានតែងតាំងជាអភិបាលម្ដងទៀត ។ លោកអភិបាល អ៊ីវ គាត់គិតដល់ព្រះសហគមន៍យើងណាស់ គាត់បានទៅទិញដីដើម្បីឱ្យយើងមានកន្លែង ជួយបង្កើតព្រះសហគមន៍សារជាថ្មីដោយមានមហាសន្និបាតប្រចាំឆ្នាំ ដើម្បីឱ្យយើងយល់ថាព្រះសហគមន៍មានជីវិត លុះត្រាតែយើងមានគណៈកម្មការសង្គហៈ គណៈកម្មការពិធីបុណ្យ គណៈកម្មការអប់រំជំនឿ ។ គាត់បានជួយឱ្យព្រះរាជាណាចក្រកម្ពុជាយើង មានទំនាក់ទំនងជាផ្លូវទូតជាមួយសន្តអាសនៈ គាត់ជួយឱ្យយើងមានលក្ខន្តិកៈនៃព្រះសហគមន៍កាតូលិកកម្ពុជា ដែលសព្វថ្ងៃលក្ខន្តិកៈនេះបានជួយយើងច្រើនណាស់ ។ គាត់បានរៀបចំទាំងអស់ ឱ្យរដ្ឋាភិបាលទទួលស្គាល់ថាព្រះសហគមន៍កាតូលិកជាសាសនា មិនមែនជាអង្គការមួយទេ ។

ក្រោយមកលោកអភិបាល អ៊ីវ បានស្នើទៅសន្តអាសនៈជ្រើសរើសលោកអភិបាលថ្មីគឺលោក អេមីល រួច ហើយគាត់ចូលនិវត្តន៍ ។ ថ្ងៃនេះគម្ពីរត្រូវនឹងជីវិតរបស់លោកអភិបាល អ៊ីវ ព្រះយេស៊ូមានព្រះបន្ទូលថា **“បើមានម្នាក់ចង់ធ្វើមេគេនៅក្នុងចំណោមអ្នករាល់គ្នា អ្នកនោះត្រូវធ្វើជាខ្ញុំបម្រើអ្នករាល់គ្នាសិន បុត្រមនុស្សមកក្នុងលោកនេះមិនមែនដើម្បីឱ្យគេបម្រើលោកទេ គឺលោកមកបម្រើគេវិញ”** ។ តាំងពីខ្ញុំស្គាល់លោកអភិបាល អ៊ីវ នៅឆ្នាំ២០០០ នៅផ្ទះលោកអភិបាលគាត់បានបម្រើភ្ញៀវខ្លាំងណាស់ នៅពេលមានជប់លៀងប្រចាំឆ្នាំ គាត់គិតទាំងអស់ ទាំងស្រា ទាំងម្ហូប ទាំងនំ ដើម្បីឱ្យបូជាចារ្យ បងប្រុសបងស្រីឱ្យចូលរួមដោយក្ដីសុខសាន្ត ។ ពេលគាត់ទៅដល់កំពង់សោមក្រោយពេលចូលនិវត្តន៍ គាត់បានលះបង់ដើម្បីជួយលោក វិរៈជ័យ លោក សុន ឱ្យរៀបចំពិធីបុណ្យ រៀបចំស្វាគមន៍ភ្ញៀវ ទៅទិញម្ហូបដែលបូជាចារ្យចូលចិត្ត គាត់គិតទាំងអស់ដូចស្ត្រីមេផ្ទះ ។ គាត់ឈឺសន្លាក់ ប៉ុន្តែគាត់មិនដែលនិយាយសោះ ពីគាត់បានវិលមកប្រទេសកម្ពុជាក្រោយខ្មែរក្រហមគាត់មិនដែលសម្រាន្តលើគ្រែទេ គឺគាត់សម្រាន្តតែលើកៅអី ។ ទោះជាយ៉ាងនេះក្ដី លោកបើកឡានខ្លួនឯងដើម្បីទៅបាត់ដំបង ប៉ោយប៉ែត ស្វាយស៊ីសុផុន សៀមរាប កំពង់សោម ដែលពេលនោះផ្លូវយ៉ាប់ណាស់ ។ នៅឆ្នាំ២០១៤ គាត់បាននិយាយថាល្មមទៅបារាំងវិញ ខ្ញុំដឹងថាគាត់ទៅវិញព្រោះមិនចង់ឱ្យយើងបម្រើគាត់វិញ គាត់ជាអ្នកបម្រើតែគាត់មិនចង់ឱ្យយើងបម្រើគាត់ទេ ។ គាត់គិតថា ប្រសិនបើគាត់នៅទីនេះចាស់ទៅពិបាកទៅ យើងត្រូវការបម្រើគាត់ ដូច្នេះគាត់សុខចិត្តលះបង់ លាក់ខ្លួនចូលនិវត្តន៍នៅប្រទេសបារាំង ។ គាត់បានឈ្នះសម័យសង្គ្រាម គាត់ឈ្នះគ្រប់កាលៈទេសៈ ជាពិសេសការឈឺចាប់ ប៉ុន្តែកូវីដ-១៩ដែលជាមេរោគដ៏តូចមួយបានឈ្នះគាត់ ។

ដូច្នេះ សូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោកអភិបាល អ៊ីវ រ៉ាមូស ដែលជាគំរូសម្រាប់ព្រះសហគមន៍កាតូលិកយើង ។ យើងមិនស្គាល់គាត់មែន ប៉ុន្តែយើងត្រូវការអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះសហគមន៍ដែលយើងមានថ្ងៃនេះ គឺដោយសារគាត់ ព្រះសហគមន៍ដែលយើងស្គាល់ថ្ងៃនេះនៅប្រទេសកម្ពុជា គឺជាផ្លែដ៏អស្ចារ្យដែលគាត់បានបង្កើត ។ នៅពេលយើងសាបព្រោះមួយគ្រាប់លើធ្លាក់លើដីមានជីជាតិ បានបង្កើត១០០គ្រាប់ គាត់បានសាបព្រោះ គាត់បានភ្ជាប់ជាមួយដីមានជីជាតិ គាត់បានណែនាំឱ្យព្រះសហគមន៍របស់យើងបង្កើតផ្លែយ៉ាងច្រើន ។ ពាក្យដែលគាត់បានជ្រើសរើស នៅពេលគាត់ទទួលអគ្គសញ្ញាតែងតាំងជាអភិបាលគឺ **“ខ្ញុំធ្វើជាលោកអភិបាល ដើម្បីឱ្យមនុស្សលោកមានជីវិត ជីវិតដ៏បរិបូណ៌”** អរគុណលោកតា ។ អាម៉ែន ៕

# The Funeral MASS
# Bishop YVES RAMOUSSE
# Homily Mgr. Kike Figaredo SJ. Prefect Apostolic of Battambang.



In the year 1998, just when the seasonal floods of Mekong River subsided, I had the chance, as a young priest, to go with Msgr. Yves Ramousse to Kompong Chomlong, a small and humble community near Neak Loeung to celebrate the Sunday Mass. As he was about to wear his mitre - the symbol of his authority as Bishop - looked at me, and said: "Do you want to wear this? This will make you always humble." I was speechless; I was in awe as I looked at him who had seen better and saddest days of the Church in Cambodia.

Since then, it had been very clear to me: Msgr. Yves Romousse was a humble person who lovingly gave his full and long life to God, serving the Church in Cambodia and all of Cambodia's people.

**A Humble Man**

In his life Mgr. Yves faced many crossroads that began with the challenges of implementing changes opened up by the Second Council of Vatican II. Then he faced many difficult situations in Cambodia and the world that was beset by confusion, instability, genocide, displacement and war.

In 1985, I met Bishop Ramousse the first time in "Evacuation Site 2", a camp for Cambodians fleeing from war inside Cambodia and sought refuge in the Thai-Cambodian border. He was so concerned and benevolent to me, a young Spanish Jesuit, who was working with disabled persons in the camp. He took great interest in our work at the Jesuit Refugee Service (JRS) and even attended the JRS Regional Annual meeting in Xavier Hall in Bangkok. He was encouraged us to accompany and to advocate the cause of Cambodian refugees and the Church of Cambodia that was so damaged by

war. He ministered tirelessly to the refugees living in the camps in Indonesia, Malaysia and Thailand reminding people about history and attended to them as a pastor full of love and caring presence. In all these, he was humble man so determined to regain the dignity and life of his people.

**A Man Faithful to God**

He was a man faithful to God by giving his all to the Church in Cambodia, adjusting to the often uncertain circumstances of a new Cambodian society that emerged after the war. He faced many diverse situations in his long years of living with and serving people of Cambodia. He has seen the days of glory, war, exile, asylum, destruction, and the days of rebuilding. He never lost faith and hope in God.

A life given in Service and Love for People of Cambodia

He loved Battambang and the areas around it. He spent his first years of living the simple life of villagers, of knowing the Cambodian church, and of learning the Khmer Language in Petyeichee (Battambang) and Chomnaom. Here, he had great memories that sealed his love and missionary commitment with Cambodia.

One of the first things he did after the war was to regain from the government the Church's ownership of the historical compound of "Petyeichee". At that time, things were not easy but he was firm in getting the land and buildings back because it was the strongest and most visible way to bring to new life the Battambang Catholic community that has been established in the same place since 1790.

In 2000, I was appointed Apostolic Prefect of Battambang. I had more encounters with Msgr. Yves. I became a member of the Bishop Conference of Laos and Cambodia (CELAC) and learned even more about his life, sense of humour, and especially about his way of proceeding in our Mission: kindness, humility and firmness.

In him I understood what "good shepherd" meant. During our annual priest retreats in Kampong Som, I saw how cared for the priests as he organized the place, food, and all other needs. He makes sure, with great fraternal care, that things are ready when needed. At CELAC meetings he was wonderful companion to all the other bishops and the happy, caring, and smooth encounters among us all naturally brought about collegiality – a spirit that Vatican II brought about in order to ensure the building up of the Church for the present times.

As I have said I am the Apostolic Prefect of Battambang. I wear a mitre. And everytime I wear this, I remember that day in 1998 when he said, "This will make you humble." I cannot forget these words because they give me strength and because they come from Msgr. Yves Ramousse, who generously gave his all to God and the people of Cambodia in humble, loving service.

Messe de sépulture de Mgr Yves Ramousse, mep
Église de Lavardac (47)
Mercredi 3 mars 2021, 15h
------
1ère lecture : Apocalypse 21,1-5a.6b-7
Psaume 22 : Le Seigneur est mon berger
Evangile : Luc 24,13-35 (les disciples d'Emmaüs)
------

Devant votre cercueil, en ce jour redouté et maintenant arrivé, Mgr Ramousse, cher Yves, je ne peux m'empêcher de penser combien l'homme est un mystère. Les messages nombreux de ceux qui vous ont connu et apprécié ouvrent comme autant de fenêtres sur la personne que vous étiez. Ces messages viennent du Cambodge, de France, d'Indonésie, de Rome, de personnes ou de groupes. Des dépêches ou des articles de journaux ont tenté de vous saisir, souvent à partir d'éléments des grandes étapes de votre vie. Et tous ces éléments sont justes :

- plus jeune évêque du monde lors de votre nomination en 1963
- un des derniers Pères conciliaires
- un des fondateurs d'une Conférence Épiscopale Laos Cambodge
- nommé deux fois évêque de Phnom Penh par le Saint Siège, puisqu'après votre expulsion du Cambodge par les Khmers Rouge en avril 1975, et la mort de votre successeur Mgr Joseph Chhmar Salas, vous avez été renommé évêque de Phnom Penh en 1992 pour rassembler la communauté survivante et en prendre soin

Mais comment aller au-delà de ces quelques faits qui vous distinguent déjà bien mais qui ne disent pas tout de l'homme que vous étiez ?
Bien sûr ce qui va suivre sera subjectif et sélectif, mais j'aimerais essayer de partager, à la lumière de la Parole de Dieu que nous avons entendu et en ayant eu la grâce de vous côtoyer comme coopérant puis comme missionnaire, quelques traits de votre personnalité et de votre vie qui laissent percer un peu votre mystère, la belle âme que vous étiez. J'aimerai le faire en 8 points assez courts :

- vous étiez un homme profondément humain, un homme « avec »
- vous étiez un authentique missionnaire
- vous étiez un homme de la célébration de la foi au cœur de la vie
- vous avez été un homme de la douleur
- vous avez été un homme de la résilience
- vous étiez un homme de la parole et de la réflexion
- vous étiez un homme du regard et du sourire
- vous avez été un pasteur doux et humble de cœur

## Vous étiez un homme profondément humain, un homme « avec », un compagnon

« Voici la demeure de Dieu parmi les hommes ; il demeurera avec eux, et ils seront ses peuples, et lui-même, Dieu avec eux, sera leur Dieu », **avons-nous entendu** dans la 1ère lecture (Ap 21).

**Cher Yves**, vous étiez un homme « avec », un homme du collectif. Toujours attentif à chacun (on se souvient avec quel soin vous accueilliez les prêtres annuellement à Sihanoukville pour la retraite annuelle en veillant à ce que les repas soient les meilleurs possibles), toujours bienveillant et compréhensif, même si vous étiez aussi exigeant pour tout ce qui touchait au bien commun et à la justice. Je ne vous ai jamais entendu critiquer pour démolir. Au contraire, vous saviez exprimer vos idées et votre point de vue avec paix, force et charité, toujours pour construire. Ce sens du collectif et votre belle humanité ont pacifié beaucoup de conflits et désamorcé des situations qui auraient pu tourner à la division.

**Merci Yves** d'avoir accompagné votre peuple avec humanité, patience et douceur. Merci d'avoir été un homme profondément humain, un homme « avec ».

## Vous étiez un missionnaire

« Jésus lui-même s'approcha, et il marchait avec eux » - « Ils se levèrent, retournèrent à Jérusalem, et il racontait ce qui s'était passé sur la route, comment le Seigneur s'était fait reconnaitre », **avons-nous entendu** dans l'évangile (Lc 24).

**Cher Yves**, vous avez quitté votre pays, la Haute-Loire, et votre Sud-Ouest, pour vous embarquer en 1957 vers le Cambodge. En faisant votre premier voyage de Saïgon à Phnom Penh, vous avez été pris d'un vertige, nous avez-vous raconté, en contemplant les populations le long de la route : « Comment pourrais-je leur parler ? M'accueilleront-elles ? » vous demandiez-vous…

Et ô combien vous ont-elles accueilli, ces populations ! Et ô combien vous-même les avez-vous rejointes ! Vous avez posé pour elles les paroles et les gestes des sacrements et de la vie en Dieu. Vous les avez soutenu et réconforté par votre enseignement, l'action caritative, en particulier dans la détresse de la guerre et des camps de réfugiés. Vous avez dialogué avec les grands : le roi, les chefs des bonzes, témoignant avec humilité de la vie rayonnante de celui qui abandonne sa vie au Christ.

**Merci Yves** pour votre témoignage. Merci d'avoir été un missionnaire du Seigneur, d'être sorti de vous-même pour aller à la rencontre de ce peuple cambodgien.

## Vous étiez un homme de la célébration de la foi au cœur de la vie

« Quand il fut à table avec eux, Jésus, ayant pris le pain, prononça la bénédiction et, l'ayant rompu, le leur donna », **avons-nous entendu** dans l'évangile (Lc 24).

**Cher Yves**, combien aimiez-vous préparer avec minutie et créativité les grandes fêtes liturgies qui rythment l'année. Pour vous, la liturgie donnait sens à la vie et la vie prenait parfois un tour liturgique. A votre premier retour à Phnom-Penh par exemple, vous étiez inquiet de savoir, après la tragédie, si vous pourriez retrouver des chrétiens. Vous avez arpenté l'artère centrale de la ville, le boulevard Norodom, et finalement quelqu'un s'est manifesté discrètement en marchant derrière vous et en vous fixant rendez-vous dans un restaurant. Nous étions en régime communiste. Vous étiez surveillé. Arrivé au rendez-vous, vous avez eu la joie de retrouver une poignée de survivants. Au cours du dîner, vous les avez chargé de la mission de redémarrer la communauté, de se réunir pour prier. Ce fut votre premier conseil pastoral d'après-guerre ! Et avant de se quitter, vous avez eu cette idée si pleine de sens de prier discrètement avec eux et de leur faire passer votre anneau épiscopal pour qu'ils l'embrassent discrètement, l'un après l'autre, en signe de communion avec vous et l'Église universelle. Quel moment fort !

Vous avez vraiment accompagné la résurrection de l'Église du Cambodge par des signes et des paroles forts et signifiants. En l'an 2000 en particulier, l'année du grand jubilé où chaque église locale était invitée à faire mémoire de ses martyrs, vous avez dessiné cette belle croix de Taing Kok, pleine de symboles (le bol cassé en mémoire de la faim, les chaînes et les barreaux en mémoire de la privation de liberté, les rizières en mémoire du travail forcé mais aussi le lotus ouvert en signe de résurrection). Cette croix, vous l'avez fait planter à Taing Kok, le lieu de la mort de votre successeur Mgr Chhmar Salas et vous avez imaginé la liturgie de l'an 2000 en demandant à chaque communauté chrétienne du Cambodge d'apporter de la terre des lieux où des fidèles avaient été martyrisés. Ce moment où, autour de la croix, la terre était déversée, préparée, et du riz nouveau semé, le riz de la résurrection, avec le chant « Si le grain tombé en terre ne meurt » avait été un grand moment pour tous les participants.

**Merci Yves** de votre grande foi. Merci de l'avoir incarné si profondément dans votre vie et celle de votre peuple, de sorte que toutes ces vies deviennent une vivante liturgie d'offrande à la gloire de Dieu.

## Vous avez été un homme de la douleur

« Il essuiera toute larme de leurs yeux, et la mort ne sera plus, et il n'y aura plus ni deuil, ni cri, ni douleur : ce qui était en premier s'en est allé », **avons-nous entendu** dans la 1ère lecture (Ap 21).

**Cher Yves**, ô combien la mort et la souffrance n'ont pas épargné votre parcours et celui du peuple cambodgien. Nul n'est besoin de faire retour sur la période Khmère Rouge. Comme le roi khmer Jayavarman VII qui écrivait que « La souffrance des hommes s'[était] muée chez lui, le roi, en une souffrance de l'âme. Et [que] cette souffrance [était] d'autant plus vive pour un roi que c'est celle du peuple et non son propre tourment. », vous avez-vous-même souffert de la souffrance de votre peuple. En quel état de délabrement physique et moral êtes-vous d'ailleurs arrivé à Bangkok après l'expulsion…

**Merci Yves** d'avoir partagé la souffrance du peuple cambodgien. Vous l'avez offerte avec celui qui s'offre Lui-même. Et vous l'avez traversée. C'est mon point suivant : « Vous avez aussi été un homme de la résilience. »

## Vous avez été un homme de la résilience

« Ils parlaient entre eux de tout ce qui s'était passé. Quand ils furent à table avec lui, ayant pris du pain, il prononça la bénédiction et, l'ayant rompu, il le leur donna. Alors leurs yeux s'ouvrirent et ils le reconnurent. A l'instant même, ils se levèrent », **avons-nous entendu** dans l'évangile (Lc 24).

**Cher Yves**, où avez-vous puisé la force, avec vos compagnons Mgr Lesouëf, les Père Venet, Destombes, Ponchaud, Rondineau, Dupraz, Toumloap Sophal, Un Son, Paul Lay, Suong Hangly, Mgr Kike, le Père Ashley, les Sœurs Marie-Jeanne, Agnès, Gilberte, Anne-Marie, Nicole Nivault (de Claire Amitié), les Ming Rumleuk, Pracot, Pracob, Sangkheum et tant d'autres dont je ne peux dire le nom, où avez-vous puisé la force de revenir au Cambodge après la guerre et de vous mettre à rebâtir l'Église avec vos frères et sœurs cambodgiens ? Où avez-vous trouvé la force de rester debout après tout ce qui avait déferlé sur le Cambodge et sa petite Église ? Comme les disciples d'Emmaüs qui se sont levés et ont bravé la nuit grâce à l'énergie de la résurrection et de la Bonne Nouvelle qu'ils venaient de percevoir, vous n'avez jamais plié et vous vous êtes remis à l'ouvrage, sans désespérer.

**Merci Yves**, de n'avoir jamais desespéré et jeté l'éponge. Merci d'avoir fondé votre résilience sur l'espérance de la résurrection et la fraternité missionnaire.

## Vous étiez un homme de la parole et de la réflexion, un sage

« Notre cœur n'était-il pas brûlant en nous, tandis qu'il nous parlait sur la route ? », avons-nous entendu dans l'évangile (Lc 24).

**Cher Yves**, votre parole était toujours mesurée et juste, jamais verbeuse ni emprunte d'éloquence mondaine, mais toujours simple, constructive, bienveillante et profonde. Elle était en phase avec votre regard dont je vais dire un mot dans le point suivant. Vous n'aviez pas peur des silences. Il ne s'agissait jamais de ces silences qui mettent mal à l'aise mais plutôt de ceux qui aident l'interlocuteur à intérioriser, à faire son propre chemin de compréhension et de réflexion.

Comme enseignant dans les séminaires à Saïgon, Phnom Penh puis Bièvre, vous avez été un homme de la parole. Comme prêtre puis évêque, vous avez commenté les évangiles, vous vous êtes nourri de la Parole de Dieu, vous l'avez prié avec le bréviaire.

**Merci Yves**, d'avoir fait raisonner en nous la Parole de Vie de votre maître et Seigneur. Merci pour votre sagesse.

## Vous étiez un homme du regard et du sourire

« Alors leurs yeux s'ouvrirent, et ils le reconnurent », avons-nous entendu dans l'évangile (Lc 24).

**Cher Yves**, accompagnant votre parole, votre interlocuteur était marqué aussi par votre regard et votre sourire. Je n'oublierai jamais votre regard. Saint Jean-Paul II écrivait dans *Redemptoris Missio* que le missionnaire est un contemplatif en action. Vous saviez voir, Yves. Vous saviez comprendre les situations, percer les sentiments, anticiper ou soulager les situations par une attention délicate.

François Ponchaud, un de vos compagnons de mission pendant des décennies, à qui je téléphonais il y a quelques jours et à qui je demandais ce qu'il retiendrait de vous m'a dit, entre autres : « Je retiendrai son sourire ».

**Merci Yves**, d'avoir su voir sans indifférence et avec intelligence les personnes et les situations. Merci aussi d'avoir toujours veillé avec le peuple khmer la fin de nuit, d'avoir été un visionnaire pour l'Église du Cambodge en jetant les bases d'une Église où les Cambodgiens se sentent bien, vraiment communautaire, ouverte à tous, catéchuménale.

Tous ces traits décrits plus haut sont autant de raisons qui montrent combien le Saint-Siège a bien fait de vous choisir, Yves, comme pasteur de l'Église au Cambodge. C'est mon dernier point : oui, vous avez été un bon pasteur, un pasteur doux et humble de cœur.

## Vous avez été un pasteur humble et doux de cœur

« Le Seigneur est mon berger : je ne manque de rien. Je ne crains aucun mal, car tu es avec moi : ton bâton me guide et me rassure », **avons-nous entendu** dans le psaume (Ps 22).

**Cher Yves**, tout ce qui précède dit combien vous avez été un bon pasteur, doux et humble de cœur. **Merci Yves**, de votre témoignage. Merci pour votre vie donnée.

Dans le bouddhisme, après les quatre nobles vérités, il y a le chemin octuple de la pratique qui rend meilleur. Ici, les huit points que je viens de souligner vous concernant, cher Yves, sont certes bien différents de ce sentier octuple du bouddhisme. Mais d'une certaine manière, il y a une correspondance entre la paix, la sagesse et la sérénité que vous dégagiez et l'âme khmère bouddhiste. On pourrait dire que vous aviez une âme khmère chrétienne, cher Yves. C'est sans doute cela qui a fait que beaucoup de nos frères et sœurs cambodgiens vous ont tant apprécié et honoré. Vous les emportez avec vous, n'en doutons pas, pour les présenter au Seigneur, et intercéder pour eux comme pour nous qui continuons notre chemin ici-bas. Pour vous maintenant, il n'y a plus ni deuil, ni cri, ni douleur. Réenfanté en Celui qui fait toutes choses nouvelles, vous êtes plus que jamais un maillon précieux qui nous relie à notre Père des Cieux. Comment le dire mieux encore, si ce n'est avec vos propres mots, avec votre propre prière :

*« Il y a toujours quelque part au monde, un lotus qui fleurit, un enfant qui sourit, un cœur qui s'épanouit. Il y a toujours quelque part deux mains levées pour la prière, deux bras ouverts pour accueillir. Il y a encore des chemins pour la paix, des marches vers la réconciliation. Il y a toujours une chance pour l'amitié, une richesse à partager. Dans cette chaîne invisible qui nous unit par-dessus océans et rivages, à travers murs et frontières, chacun de nous est un maillon précieux. Chacun de nous est tour à tour : celui qui donne et celui qui reçoit ; celui qui réconforte et celui qui est libéré. Tu nous as réenfantés, Seigneur, pour une espérance vivante, ravive le souffle de notre espérance, donne-nous de grandir dans la fraternité ».*

**Ainsi soit-il.**
**Mgr Yves Ramousse** (1928-2021)

Merci Yves.

Vincent Sénéchal, mep
Missionnaire du Cambodge

# សក្ខីភាពរបស់លោកបូជាចារ្យ សិលា ទម្លាប់ សុផល
# អំពីលោកអភិបាល អ៊ីវ រ៉ាមូស



នៅគ្រាដំបូង មិនសូវជាមានអ្វីគួរឱ្យកត់សម្គាល់ ព្រោះខ្ញុំបានទទួលអគ្គសញ្ញាពីលោកអភិបាល Rabolland ។ លុះដល់ឆ្នាំ១៩៦៨ ខ្ញុំមានអាយុ១៥ឆ្នាំ ពេលព្រះវិហារព្រះនាងម៉ារី ដែលមិនជំពាក់បាប មានពិធីបុណ្យសំខាន់ៗ ដូចជា៖ ព្រះកាយព្រះលោហិតព្រះគ្រីស្ត បុណ្យខួបព្រះវិហារព្រះនាងម៉ារីមិនជំពាក់បាប បុណ្យនាងម៉ារីឡើងឋានបរមសុខ... ភាគច្រើនខ្ញុំជាក្រុមកុមារដែលកាន់ទងក្នុងក្បួនដង្ហែរ ពេលនោះបានមើលឃើញពីចម្ងាយ ឬពេលធ្វើអគ្គសញ្ញាលាបថ្វាស ខ្ញុំអង្គុយសម្លឹងមើលលោកពីចម្ងាយ ។

ឆ្នាំ១៩៧០ សង្គ្រាមមកដល់ខ្ញុំដាច់ទំនាក់ទំនងជាមួយលោកបូជាចារ្យ (MEP) ទាំងស្រុង រហូតដល់ចុងឆ្នាំ១៩៨២ លោកឪពុក Robert Venet ស្វែងរកខ្ញុំឱ្យជួយអប់រំជំនឿនៅជំរុំ ខាវអ៊ីដាង សាជាថ្មី ខ្ញុំចាប់ផ្ដើមជួបលោកអភិបាល អ៊ីវ រ៉ាមូស នៅក្នុងជំរុំម្ដងម្កាល តែពុំសូវបាននិយាយអ្វីបានច្រើនទេ លោកគ្រាន់តែមកមើលអ្វីដែលខ្ញុំកំពុងធ្វើ... រហូតដល់ខ្ញុំមានឈ្មោះចេញទៅកាណាដា (កេបិច១ឆ្នាំកន្លះ) ក៏ប្ដូរទីលំនៅទៅនៅម៉ុងត្រេអាលវិញ ។ នៅម៉ុងត្រេអាល ដែលខ្ញុំឮការត្រាស់ហៅរួចបានចូលរៀនក្នុងទេវវិទ្យាល័យបាន៥ឆ្នាំ ។

សង្ខេបយ៉ាងខ្លី សក្ខីភាពរវាងខ្ញុំនិងលោក អ៊ីវ រ៉ាមូស គឺតាំងពីថ្ងៃទី២២-២៨ ខែធ្នូ ឆ្នាំ១៩៨៩ មានសារៈសំខាន់ ព្រោះក្នុងខែធ្នូ ឆ្នាំ១៩៨៩ ខ្ញុំមានឧត្តមគតិមួយគិតថានៅម៉ុងត្រេអាល មានបូជាចារ្យច្រើន មានលោកអភិបាល ថែមទាំងមានកាឌីណាល់ផងដែរ ។ ហេតុនេះ ខ្ញុំជាជនជាតិអាស៊ីមួយសេសសល់ក្នុងចំណោមគេ បានជាខ្ញុំសម្រេចឈប់តាមការត្រាស់ហៅជាបូជាចារ្យ ចាកចេញទៅធ្វើការរកស៊ីធម្មតាវិញ ។ ខ្ញុំក៏បានរៀបចំកេះសៀវភៅ វ៉ាលីដាក់ខោអាវរង់ចាំថ្ងៃឈប់សម្រាក់បុណ្យព្រះយេស៊ូប្រសូតចប់ ខ្ញុំទៅជួបលោកនាយកទេវវិទ្យាល័យ (Lionel Gendron) រួចចេញទៅ ។ ចន្លោះពេលពីថ្ងៃទី២២-២៨ ខែធ្នូ ឆ្នាំ១៩៨៩ លោកអភិបាល អ៊ីវ រ៉ាមូស លោក ប៉ុងសូដ៍ លោក វើណេ លោកទាំងបីត្រូវបានព្រះជាម្ចាស់ផ្ញើឱ្យមករកខ្ញុំចំពេលត្រូវការ ព្រោះខ្ញុំមិនចូលចិត្តនៅបម្រើភូមិភាគម៉ុងត្រេអាល ។ ហេតុនេះ លោកទាំងបីដោយមិនដឹងថាខ្ញុំឈប់ពីទេវវិទ្យាល័យ លោកទាំងបីស្វែងរកជួបខ្ញុំ ដើម្បីនិយាយអំពីស្ថានភាពព្រះសហគមន៍នៅប្រទេសកម្ពុជានាឆ្នាំ១៩៨៩ ឱ្យខ្ញុំដឹងជាព័ត៌មាន ។ តាំងពីចាកចេញពីប្រទេសកម្ពុជាឆ្នាំ១៩៧០ ខ្ញុំមិនដឹងអ្វីទាំងអស់ពីព្រះសហគមន៍កម្ពុជា ។

ក្រោយពីទទួលដំណឹងពីលោកទាំងបី ចិត្តខ្ញុំចាប់ផ្ដើមផ្លាស់ប្រែ ដោយគិតថាពេលនេះសម្លេងនៃការត្រាស់ហៅច្បាស់ ព្រះជាម្ចាស់រៀបចំផ្លូវឲ្យខ្ញុំសម្រាប់ព្រះសហគមន៍មួយនេះ ។ រួចហើយលោកអភិបាល អ៊ីវ រ៉ាមូស បានសំណូមពរប្រសិនបើខ្ញុំចាប់អារម្មណ៍ត្រឡប់ទៅជួយស្រុកខ្មែរ **"ចូរធ្វើពាក្យសុំ"** ។ ក្រោយពេលធ្វើពាក្យសុំ

លោកអភិបាលដកខ្ញុំចេញពីទេវវិទ្យាល័យ ម៉ុងត្រេអាល់ ទៅទេវវិទ្យាល័យសន្តអ៊ីរេណេ នៅទីក្រុងលីយ៉ុង ប្រទេសបារាំង ដើមឆ្នាំ១៩៩០ ។ ក្រោយសិក្សារយៈពេលបួនឆ្នាំនៅក្រុងលីយ៉ុងបានបញ្ចប់ ខ្ញុំត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៩៤ ។ ទីបញ្ចប់លោកអភិបាល អ៊ីវ រ៉ាមូស បានធ្វើអគ្គសញ្ញាតែងតាំងខ្ញុំជាបូជាចារ្យនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៥ រូបខ្ញុំនេះក៏ជាបេក្ខជនចុងក្រោយដែលលោកបានតែងតាំង ។

ការចាត់តាំងដំបូង គឺលោកបានចាត់ខ្ញុំឱ្យទៅនៅតំបន់កំពង់ធំ ដែលមាន៖ ព្រះសហគមន៍កំពង់គោ ព្រៃកស្បូវ កំពង់រទេះ បល័ង្ក ម្ទារ ព្រះសហគមន៍ភូមិប៉ាង ឯតាំងគោកជាដីមរណៈសាក្សី ។

អនុស្សាវរីយ៍ការផ្លាស់ប្ដូរទីកន្លែង ពេលនោះនៅព្រះវិហារកំពង់រទេះ ខ្ញុំកំពុងបម្រើយជំបូលដាក់ជួង ជាហេតុបីដងខ្ញុំប្រកែក ការចាត់តាំងរបស់លោកអភិបាល ដោយសុំអនុញ្ញាតឱ្យខ្ញុំបម្រើយកិច្ចការនេះសិន ។ នៅលើកទី៣ លោកបានប្រើសំនួនភាសាក្នុងនាមជាអភិបាល **«ខ្ញុំសូមចាត់លោកឱ្យទៅបាត់ដំបង ព្រោះគ្មានលោកណាផ្សេង ចូរស្ដាប់បង្គាប់ខ្ញុំ»** ខ្ញុំក៏យល់ព្រមចេញទៅ ។ រីឯលោក ហ្វ្រង់កូ Franco ក៏ត្រូវស្ដាប់បង្គាប់ទទួលយកតំបន់កំពង់ធំ ទោះបីគាត់កំពុងរៀនភាសាខ្មែរនៅឆ្នាំទី២ ។

អនុស្សាវរីយ៍មួយទៀត ដោយយល់ថាតំបន់បាត់ដំបងធំហើយមានតែខ្ញុំនៅម្នាក់ឯង ដើម្បីលើកទឹកចិត្តនិងការពិភាក្សាការងារលោក អ៊ីវ រ៉ាមូស ខិតខំបើកឡានពីភ្នំពេញមកបាត់ដំបងបីដងតែម្នាក់ឯង ទាំងផ្លូវពិបាក លោកបែកកង់ឡាន២លើក ត្រូវទុកឡានចោលយកកង់ឡានទៅប៉ះរួចវិលមកវិញចាប់កង់ចូល ។

អនុស្សាវរីយ៍ ដើរក្នុងទឹកភក់ស្អុយនៅប៉ោយប៉ែតស្វែងរកទិញដី មុនដំបូងមានលោកឪពុក Bob លើកទី២ មានលោកឪពុក អូលីវីយ៉េ លើកទី៣ ខ្ញុំទៅទិញផ្ទះមួយ ។

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៣ មុនពេលលោកសម្រេចចិត្តចាកចេញពីស្រុកខ្មែរ លោកអភិបាល អ៊ីវ បានអញ្ជើញលោកបូជាចារ្យខ្មែរទាំង៩នាក់ មករួមថ្វាយអភិបូជានៅលើដីមរណសាក្សីនៅតាំងគោក ។ ជាកិច្ចអរព្រះគុណព្រះជាម្ចាស់ នូវសក្ខីភាពដែលបងប្អូនឆ្លើយតបនឹងព្រះជាម្ចាស់ ជាមួយជំនឿរបស់បងប្អូនដែលជាហេតុនាំគេត្រឡប់ទៅឯព្រះអង្គវិញ ។ លោកចង់ឱ្យបូជាចារ្យខ្មែរក្នុងស្រុក ចេះរួបរួមគ្នាតស៊ូបម្រើព្រះសហគមន៍តាមជំនឿ និងកំរិតយល់ដឹងរៀងៗខ្លួន ។

សូមព្រះជាម្ចាស់ប្រទានពរឱ្យលោកក្លាយទៅជាអ្វីដែលលោកបានប្រារព្ធ និងទទួលទានរាល់ថ្ងៃគឺព្រះកាយព្រះគ្រីស្ត ។ អាម៉ែន ៕

# សក្ខីភាពរបស់លោកបូជាចារ្យ យ៉ូហាន អ៊ុន សុន
# អំពីលោកអភិបាល អ៊ីវ រ៉ាមូស



ជាបឋមខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ និងសូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ! **"ព្រះជាម្ចាស់ដែលបានត្រាស់ហៅលោក ធ្វើជាអ្នកបម្រើតាំងពីលោកនៅក្នុងផ្ទៃម្ដាយមកម្លេះ"** (អេសាយ៤៩,១) តាមរយៈលោកអភិបាលដែលបានណែនាំខ្ញុំឱ្យស្គាល់ព្រះសហគមន៍ និងបានមកបម្រើព្រះសហគមន៍នៅស្រុកខ្មែរ ។

